ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥-០១៤-០៦៤ ប្រ.ក

# ប្រកាស
## ស្តីពី
## ការផ្ទេរប្រាក់ក្រៅប្រទេសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈធនាគារជាតិនៃកម្ពុជា

------

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ ។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់នីតិវិធី និងកម្រៃសេវានៃការផ្ទេរប្រាក់ក្រៅប្រទេសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈធនាគារជាតិនៃកម្ពុជា ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ២.~**

ប្រកាសនេះអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ៣.~**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចផ្ទេរប្រាក់ជារូបិយប័ណ្ណតាមរយៈធនាគារជាតិនៃកម្ពុជា ។

**ប្រការ៤.~**

ធនាគារជាតិនៃកម្ពុជានឹងចាត់ចែងធ្វើប្រតិបត្តិការផ្ទេរប្រាក់ទៅតាមពេលវេលាដូចខាងក្រោម៖

- មុនម៉ោង១១ព្រឹក: ឯកសារផ្ទេរប្រាក់នឹងត្រូវចាត់ចែងធ្វើប្រតិបត្តិការក្នុងថ្ងៃ
- ក្រោយម៉ោង១១ព្រឹក: ឯកសារផ្ទេរប្រាក់នឹងត្រូវរក្សាទុកសម្រាប់ធ្វើប្រតិបត្តិការនាថ្ងៃធ្វើការបន្ទាប់ ។

**ប្រការ៥.~**

ការផ្ទេរប្រាក់ទៅធនាគារទទួលផលតែមួយ ត្រូវអនុលោមទៅតាមបរិមាណប្រាក់នៃប្រតិបត្តិការជាក់ស្តែង និងមានថ្ងៃប្រសិទ្ធភាពដូចខាងក្រោម៖

- ទំហំប្រាក់ផ្ទេរតូចជាង ៨០ពាន់លានរៀល ឬ សមមូល ថ្ងៃប្រសិទ្ធភាពនៃប្រតិបត្តិការផ្ទេរប្រាក់ គឺមួយថ្ងៃបន្ទាប់ពីបានចុះឥណពន្ធគណនីចរន្ត (t+1)
- ទំហំប្រាក់ផ្ទេរចាប់ពី ៨០ពាន់លានរៀល ឬ សមមូល ថ្ងៃប្រសិទ្ធភាពនៃប្រតិបត្តិការផ្ទេរប្រាក់ គឺពីរថ្ងៃបន្ទាប់ពីបានចុះឥណពន្ធគណនីចរន្ត (t+2) ។

**ប្រការ៦.~**

ឯកសារផ្ទេរប្រាក់ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវប្រគល់ជូនធនាគារជាតិនៃកម្ពុជា មានដូចខាងក្រោម៖

- បញ្ជាផ្ទេរប្រាក់ក្រៅប្រទេស (Oversea Transfer Order) (ទម្រង់គំរូ ឧបសម្ព័ន្ធ១)
- តារាងប្រភពនិងការប្រើប្រាស់ទុនក្នុងស្រុក (Local Sources and Uses of Fund) (ទម្រង់គំរូ ឧបសម្ព័ន្ធ២) និង
- ឯកសារពាក់ព័ន្ធ តាមការចាំបាច់ ។

**ប្រការ៧.~**

កម្រៃសេវាផ្ទេរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគិតលើចំនួនប្រាក់ដែលត្រូវផ្ទេរ ដោយកាត់ចេញពីគណនីចរន្ត នៅធនាគារជាតិនៃកម្ពុជា តាមការកំណត់ដូចខាងក្រោម៖

ក- ប្រាក់ផ្ទេរពីបរទេស

- ០,១២% នៃប្រាក់ផ្ទេរចូល
- អប្បបរមា ៣០.០០០ រៀល ឬសមមូល
- អតិបរមា ៩.០០០.០០០រៀល ឬសមមូល

ខ- ប្រាក់ផ្ទេរទៅបរទេស

- ០,១២% នៃប្រាក់ផ្ទេរចេញ
- អប្បបរមា ៣០.០០០ រៀល ឬសមមូល និង
- ថ្លៃ SWIFT ១២០.០០០រៀល ក្នុងមួយប្រតិបត្តិការ

**ប្រការ៨.~**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនត្រូវបានអនុញ្ញាតឲ្យនាំចេញសាច់ប្រាក់ជាដុល្លារអាមេរិកទៅក្រៅប្រទេសដោយខ្លួនឯងឡើយ ។

**ប្រការ៩.~**

ត្រូវចាត់ទុកជានិរាករណ៍នូវ៖

- ប្រកាសលេខ ធ៩៩៨-៤១១ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជតាមរយៈធនាគារជាតិនៃកម្ពុជា
- សេចក្តីជូនដំណឹងលេខ ធ៥.០៧-១៨៦សជណ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ស្តីពីបែបបទផ្ទេរប្រាក់ទៅក្រៅប្រទេស
- សេចក្តីជូនដំណឹងលេខ ធ៥.០៨-៥៦១សជណ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីកម្រៃសេវាផ្ទេរប្រាក់ជារូបិយប័ណ្ណតាមរយៈធនាគារជាតិនៃកម្ពុជា
- សេចក្តីជូនដំណឹងបន្ថែមលេខ ធ៥១១-០២៨៩សជណ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ព្រមទាំងរាល់ខ្លឹមសារទាំងឡាយណាដែលផ្ទុយពីស្មារតីនៃ ប្រកាសនេះ ។

**ប្រការ១០.~**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានប្រតិស្រុតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ១១.~**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤

ទេសាភិបាល

**ជា.ចាន់តូ**

**កន្លែងទទួល៖**
- ដូចប្រការ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**
- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

Bank Logo

**ឧបសម្ព័ន្ធ ១**

**បញ្ជាផ្ទេរប្រាក់ក្រៅប្រទេស**

Oversea Transfer Order

---------------

- ចំនួនប្រាក់ / Amount: ..............................................................................................
- អ្នកទទួលប្រាក់ / Beneficiary's Name: .......................................................................
- លេខគណនី / Account Number: ...................................................................................
- ធនាគារអ្នកទទួលប្រាក់ / Beneficiary's Bank: ..............................................................

  អាស័យដ្ឋាន / Address: ..............................................................................................

  Swift Code: ...............................................................................................................
- ធនាគារអន្តរការី ឬធនាគារទំនាក់ទំនងរបស់ធនាគារអ្នកទទួលប្រាក់ / Intermediary Bank or Correspondent Bank: ..............................................................................................

  អាស័យដ្ឋាន / Address: ..............................................................................................

  Swift Code: ...............................................................................................................
- គោលបំណងនៃការទូទាត់ / Purpose of payment: ..........................................................
- សូមចុះឥណពន្ធកម្រៃសេវាធនាគារពី / Deduct Bank Charge from:

  ☐ អ្នកផ្ទេរប្រាក់ / Debit from drawer's account

  ☐ អ្នកទទួលផល / Debit from beneficiary amount

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ធនាគារ**......................

Bank Logo

**ឧបសម្ព័ន្ធ ២**

## តារាងប្រភពនិងការប្រើប្រាស់ទុនក្នុងស្រុក

Local Source and Use of Fund

ថ្ងៃទី ខែ ឆ្នាំ

---------------

| **ការប្រើប្រាស់ទុនក្នុងស្រុក** ( Fund Used Locally ) | **ចំនួនប្រាក់** |
|---|---|
| ១.សាច់ប្រាក់ (Cash)<br>២.ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា (Deposits with NBC)<br>ដក ប្រាក់តម្កល់ធានាលើដើមទុន (Minus capital guarantee)<br>៣.ប្រាក់បញ្ញើនៅធនាគារក្នុងស្រុក(Deposits with local banks)<br>៤.ប្រាក់ឲ្យខ្ចីចងការនិងបុរេប្រទានសុទ្ធ (Net loans and advances)<br>សរុបទុនដែលបានប្រើប្រាស់ I | |
| **ប្រភពទុនក្នុងស្រុក**( Fund Collected Locally ) | |
| ១.ប្រាក់បញ្ញើទទួលពីអតិថិជនក្នុងស្រុក (Deposits from local customer)<br>២.ប្រាក់បញ្ញើរបស់ធនាគារក្នុងស្រុក (Deposits from local bank)<br>សរុបប្រភពទុន II | |
| **បម្រែបម្រួល** = I – II<br>**អនុបាត** = I / II | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ធនាគារ**.........................